**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកិច្ចការនារី**

លេខ......១០៩២........ កកន/សរណ

# សេចក្តីជូនដំណឹង
## ស្តីពីការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការ និងនិស្សិត ឱ្យចូលបម្រើការងារក្នុងក្របខ័ណ្ឌក្រសួងកិច្ចការនារី សម្រាប់ឆ្នាំ២០១៩

**យោង** : លិខិតលេខ ១០៩៧ មស.ក្រខ ចុះថ្ងៃពុធ ១កើត ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៩ របស់ក្រសួងមុខងារសាធារណៈ ។

ក្រសួងកិច្ចការនារី សូមជូនដំណឹងដល់មន្ត្រីរាជការ និងនិស្សិត ឱ្យបានជ្រាបថា ៖ ក្រសួងនឹងរៀបចំការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការ និងនិស្សិតឱ្យចូលបម្រើការងារក្នុងក្របខ័ណ្ឌក្រសួងកិច្ចការនារីចំនួន **៤០ កន្លែង** ក្របខ័ណ្ឌ "**ក**" សម្រាប់ឆ្នាំ២០១៩ ដូចខាងក្រោម ៖

**ក- ទីស្តីការក្រសួង ជ្រើសរើសចំនួន ៦ កន្លែង**

១. ជំនាញវិទ្យាសាស្ត្រសេដ្ឋកិច្ច ចំនួន ១កន្លែង
២. ជំនាញព័ត៌មានវិទ្យា ចំនួន ២កន្លែង
៣. ជំនាញនីតិសាស្ត្រ ចំនួន ២កន្លែង
៤. ជំនាញវិទ្យាសាស្ត្រសង្គម ចំនួន ១កន្លែង

**ខ- មន្ទីរកិច្ចការនារីរាជធានី ខេត្ត ជ្រើសរើសចំនួន ៣៤ កន្លែង**

១. មន្ទីរកិច្ចការនារីរាជធានីភ្នំពេញ ចំនួន ១ កន្លែង
២. មន្ទីរកិច្ចការនារីខេត្តកណ្តាល ចំនួន ១ កន្លែង
៣. មន្ទីរកិច្ចការនារីខេត្តកំពង់ចាម ចំនួន ១ កន្លែង
៤. មន្ទីរកិច្ចការនារីខេត្តកំពង់ឆ្នាំង ចំនួន ១ កន្លែង
៥. មន្ទីរកិច្ចការនារីខេត្តកំពង់ស្ពឺ ចំនួន ១ កន្លែង
៦. មន្ទីរកិច្ចការនារីខេត្តកំពង់ធំ ចំនួន ១ កន្លែង
៧. មន្ទីរកិច្ចការនារីខេត្តពោធិ៍សាត់ ចំនួន ២ កន្លែង
៨. មន្ទីរកិច្ចការនារីខេត្តព្រៃវែង ចំនួន ៣ កន្លែង
៩. មន្ទីរកិច្ចការនារីខេត្តស្វាយរៀង ចំនួន ២ កន្លែង
១០. មន្ទីរកិច្ចការនារីខេត្តតាកែវ ចំនួន ២ កន្លែង
១១. មន្ទីរកិច្ចការនារីខេត្តកំពត ចំនួន ១ កន្លែង
១២. មន្ទីរកិច្ចការនារីខេត្តកោះកុង ចំនួន ១ កន្លែង
១៣. មន្ទីរកិច្ចការនារីខេត្តបាត់ដំបង ចំនួន ១ កន្លែង
១៤. មន្ទីរកិច្ចការនារីខេត្តបន្ទាយមានជ័យ ចំនួន ១ កន្លែង
១៥. មន្ទីរកិច្ចការនារីខេត្តសៀមរាប ចំនួន ១ កន្លែង
១៦. មន្ទីរកិច្ចការនារីខេត្តព្រះវិហារ ចំនួន ១ កន្លែង
១៧. មន្ទីរកិច្ចការនារីខេត្តក្រចេះ ចំនួន ១ កន្លែង
១៨. មន្ទីរកិច្ចការនារីខេត្តស្ទឹងត្រែង ចំនួន ១ កន្លែង
១៩. មន្ទីរកិច្ចការនារីខេត្តរតនគិរី ចំនួន ១ កន្លែង
២០. មន្ទីរកិច្ចការនារីខេត្តមណ្ឌលគិរី ចំនួន ១ កន្លែង

២១. **មន្ទីរកិច្ចការនារីខេត្តឧត្តរមានជ័យ** ចំនួន **១ កន្លែង**
២២. **មន្ទីរកិច្ចការនារីខេត្តព្រះសីហនុ** ចំនួន **២ កន្លែង**
២៣. **មន្ទីរកិច្ចការនារីខេត្តកែប** ចំនួន **២ កន្លែង**
២៤. **មន្ទីរកិច្ចការនារីខេត្តប៉ៃលិន** ចំនួន **២ កន្លែង**
២៥. **មន្ទីរកិច្ចការនារីខេត្តត្បូងឃ្មុំ** ចំនួន **២ កន្លែង**

មន្ត្រីរាជការ និងនិស្សិត ដាក់ពាក្យប្រឡងចូលបម្រើការងារនៅមន្ទីរកិច្ចការនារីរាជធានី ខេត្ត មិនត្រូវបានអនុញ្ញាត ចំពោះសញ្ញាបត្រជំនាញធ្មប ពេទ្យសត្វ វិស្វកម្ម និងសំណង់ស៊ីវិល ។

## គ- លក្ខខណ្ឌនៃការជ្រើសរើស ៖

- ត្រូវមានសញ្ជាតិខ្មែរ
- បេក្ខជនត្រូវមានអាយុច្រើនបំផុត ៣៥ឆ្នាំ (កើតឆ្នាំ១៩៨៤) ករណីមានសញ្ញាបត្របរិញ្ញាបត្រ
- បេក្ខជនត្រូវមានអាយុច្រើនបំផុត ៤០ឆ្នាំ (កើតឆ្នាំ១៩៧៩) ករណីមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់
- ត្រូវបានលើកលែងលក្ខខណ្ឌអាយុ ចំពោះបេក្ខជនជាមន្ត្រីរាជការ និងបេក្ខជនជានិស្សិតដែលមានសញ្ញាបត្រថ្នាក់បណ្ឌិតឡើងទៅ
- ត្រូវមានលិខិតអនុញ្ញាតពីប្រធានស្ថាប័ន ចំពោះបេក្ខជនជាមន្ត្រីរាជការ
- ផ្តល់អាទិភាពនិងលើកទឹកចិត្តចំពោះនិស្សិត និងមន្ត្រីរាជការជាជនជាតិដើមភាគតិច ជនពិការ និងស្ត្រី និង
- ផ្តល់អាទិភាពនិងលើកទឹកចិត្តចំពោះមន្ត្រីជាប់កិច្ចសន្យាក្រសួងកិច្ចការនារីដែលបានបម្រើការងារចាប់ពី៥ឆ្នាំឡើង

## ឃ- កាលបរិច្ឆេទ និងទីកន្លែងទទួលពាក្យសុំប្រឡង

មន្ត្រីរាជការ និស្សិត ដែលមានបំណងចង់ប្រឡងប្រជែងចូលបម្រើការងារក្នុងក្របខ័ណ្ឌក្រសួងកិច្ចការនារី ត្រូវមកដាក់ពាក្យសុំចុះឈ្មោះប្រឡងនៅទីស្តីការក្រសួងកិច្ចការនារី ដែលមានអាសយដ្ឋាន ផ្លូវទ្រុងមាន់ ភូមិដំណាក់ធំ៣ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ **(នាយកដ្ឋានរដ្ឋបាល បុគ្គលិក) និងមន្ទីរកិច្ចការនារីរាជធានី ខេត្ត ចាប់ពីថ្ងៃទី២៤ ខែមិថុនា ដល់ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៩ រៀងរាល់ម៉ោងធ្វើការ** ។

ចំពោះព័ត៌មានផ្សេងៗ សូមទំនាក់ទំនងមកនាយកដ្ឋានរដ្ឋបាល បុគ្គលិកតាមរយៈលេខទូរស័ព្ទ ០១៦ ៦១២ ៤៥៩ / ០១៧ ៣៣៣ ៦១៣ / ០៩៧ ២១៤ ៧៩៤៣ និងមន្ទីរកិច្ចការនារីរាជធានី ខេត្ត នៃក្រសួងកិច្ចការនារីរៀងរាល់ម៉ោងធ្វើការ (ចាប់ពីម៉ោង ៧:៣០នាទី ដល់ម៉ោង ១៧:០០នាទី ។

## ង- សំណុំលិខិតសុំចុះឈ្មោះប្រឡងមាន ៖

| | |
|---|---|
| -ពាក្យសុំចុះឈ្មោះប្រឡង | ចំនួន ០១ច្បាប់ |
| -ជីវប្រវត្តិសង្ខេប មានបិទរូបថតថ្មី ៤ X ៦ | ចំនួន ០១ច្បាប់ |
| -សលាកប័ត្រឯកត្តជន មានបិទរូបថតថ្មី ៤ X ៦ | ចំនួន ០២ច្បាប់ |
| -បង្កាន់ដៃទទួលពាក្យបង់ប្រាក់សុំសិទ្ធិប្រឡង | ចំនួន ០២ច្បាប់ |
| -កិច្ចសន្យាបម្រើការងារក្នុងក្របខ័ណ្ឌក្រសួងកិច្ចការនារី | ចំនួន ០១ច្បាប់ |
| -លិខិតអនុញ្ញាតពីប្រធានស្ថាប័ន (បេក្ខជនជាមន្ត្រីរាជការ) | ចំនួន ០១ច្បាប់ |
| -សេចក្តីចម្លងសញ្ញាបត្រដោយមានការបញ្ជាក់ទទួលស្គាល់ផ្លូវការ | ចំនួន ០១ច្បាប់ |
| -សេចក្តីចម្លងប័ណ្ណគ្រួសារ/សៀវភៅស្នាក់នៅ | ចំនួន ០១ច្បាប់ |
| -សេចក្តីចម្លងអត្តសញ្ញាណប័ណ្ណ/សំបុត្រកំណើត | ចំនួន ០១ច្បាប់ |
| -លិខិតបញ្ជាក់សុខភាព (ពេលប្រឡងជាប់) | ចំនួន ០១ច្បាប់ |
| -លិខិតថ្កោលទោស (ពេលប្រឡងជាប់) | ចំនួន ០១ច្បាប់ |

មន្ត្រីរាជការ និងនិស្សិតអាចទាញយកពាក្យសុំចុះឈ្មោះប្រឡងចូលបម្រើការងារក្នុងក្របខ័ណ្ឌក្រសួងកិច្ចការនារី សម្រាប់ឆ្នាំ២០១៩ នៅលើគេហទំព័រក្រសួងកិច្ចការនារី www.mowa.gov.kh និងPage facebook.com / mowa.gov.kh (Ministry of Women's Affairs of Cambodia) ។

**ច- ការលបរិច្ឆេទ និងមណ្ឌលប្រឡង ៖**

- **កាលបរិច្ឆេទ** ៖ ថ្ងៃអាទិត្យ ១១កើត ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី១១ **ខែសីហា ឆ្នាំ២០១៩** វេលាម៉ោង ៧ : ០០នាទីព្រឹក
- **មណ្ឌលប្រឡង** ៖ ជូនដំណឹងនៅពេលក្រោយ
- **វិញ្ញាសាប្រឡង** ៖ **សម្រាប់មន្ត្រីរាជការ និងនិស្សិត ប្រឡងចូលក្នុងក្របខ័ណ្ឌក្រសួងកិច្ចការនារី ៖**
  - ១.វប្បធម៌ទូទៅ រយៈពេល ១ : ៣០នាទី
  - ២.កិច្ចការនារី រយៈពេល ២ : ០០នាទី
  - ៣.ភាសាអង់គ្លេស រយៈពេល ១ : ០០នាទី (សម្រាប់ទីស្តីការក្រសួង) ៗ/

ថ្ងៃសុក្រ ៤រោច ខែជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែមិថុនា ឆ្នាំ២០១៩

**រដ្ឋមន្ត្រី**

**អ៊ឹង កន្ថាផាវី**

<u>ចម្លងជូន</u>

- គ្រប់ក្រសួង-ស្ថាប័ន "ដើម្បីផ្សព្វផ្សាយ"
- នាយកដ្ឋានព័ត៌មាន "ដើម្បីផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ គេហទំព័រ និងផេករបស់ក្រសួង"
- មន្ទីរកិច្ចការនារីរាជធានី ខេត្ត "ដើម្បីមុខការ"